**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥៤៨ ប្រក.កសក

លិខិតចូល

ថ្ងៃទី ០៣ ខែ ១០ ឆ្នាំ 2010

# ប្រកាស

## ស្តីពី

## ការបង្កើត និង ការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តកំពត

### រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

- បានឃើញប្រកាសលេខ ២១៩ ប្រក.កសក ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ

## សម្រេច

**ប្រការ ១.-**

បង្កើតតំបន់ព្រៃសហគមន៍ក្នុងខេត្តកំពត សម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តរភាពតាមលក្ខណៈសហគមន៍ព្រៃឈើ ដែលមានទីតាំងស្ថិតក្នុងផ្នែករដ្ឋបាលព្រៃឈើឈូក នៃខណ្ឌរដ្ឋបាលព្រៃឈើកំពត ។

**ប្រការ ២.-**

ការបង្កើតតំបន់ព្រៃសហគមន៍ក្នុងគោលបំណង :

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្ស និង អភិវឌ្ឍព្រៃសហគមន៍ឱ្យមាននិរន្តរភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើ ជាលក្ខណៈប្រពៃណី សម្រាប់ការរស់នៅ ទំនៀមទម្លាប់ និងជំនឿសាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមសក្តានុពល និង លទ្ធភាពធនធានព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

**ប្រការ ៣.-**

តំបន់ព្រៃសហគមន៍ក្នុងខេត្តកំពតនៃប្រកាសនេះមាន ០៨ សហគមន៍ព្រៃឈើ ចែកចេញជា ១០ កន្លែង ដែលមានផ្ទៃដីសរុបចំនួន ៣.៨១៩ (បីពាន់ប្រាំបីរយដប់ប្រាំបួន) ហិកតា ដូចមានក្នុងផែនទីទីតាំងព្រៃសហគមន៍ និង ផែនទីសហគមន៍នីមួយៗភ្ជាប់ជាឧបសម្ព័ន្ធ១ នៃប្រកាសនេះ និងជាប្រព័ន្ធខ្សែព្រំប្រទល់ កំណត់ដោយចំណុចគោល និងនិយាមកា ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ ។

**ប្រការ ៤.-**

ដំណើរការរៀបចំនិងការប្រព្រឹត្តិទៅនៃសហគមន៍ព្រៃឈើនៅក្នុងតំបន់ព្រៃសហគមន៍ដែលបានកំណត់ក្នុងប្រកាសនេះត្រូវអនុវត្តតាមនីតិវិធី ដូចបានកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ។

**ប្រការ ៥.-**

ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៦._

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយដ្ឋានផែនការនិងស្ថិតិ ប្រធានមន្ទីរកសិកម្មខេត្តកំពត និង ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ០៣ ឆ្នាំ២០១០

រដ្ឋមន្ត្រី

ច័ន្ទ-សារុន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តកំពត
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ



ឧបសម្ព័ន្ធ ២ : ភ្ជាប់ប្រកាសលេខ ៥៤៥..... ចុះថ្ងៃទី ២១..ខែ ..កក្កដា.... ឆ្នាំ ២០១០....

## ទីតាំងព្រៃសហគមន៍ក្នុងខេត្តកំពត

| ល.រ | ឈ្មោះសហគមន៍ | ផ្ទៃដី (ហិកតា) | និយាមការ UTM កំណត់បណ្តាញប្រព័ន្ធពិភាគ ឥណ្ឌា ១៩៦០ | | | | | | | ភូមិ | ឃុំ | ស្រុក | ផ្នែករដ្ឋបាល ព្រៃឈើ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ភ្នំចងឯក | ៦៩ | កើត | A | 416971 | 1213842 | B | 416632 | 1213084 | ១ | តាកែន | ឈូក | ឈូក |
| | | | ត្បូង | B | 416632 | 1213084 | C | 416032 | 1213488 | | | | |
| | | | លិច | C | 416032 | 1213488 | D | 416267 | 1214298 | | | | |
| | | | ជើង | D | 416267 | 1214298 | E | 416555 | 1214216 | | | | |
| | | | | E | 416555 | 1214216 | A | 416971 | 1213842 | | | | |
| ២ | ស្រែលាវ | ៣១ | កើត | A | 420269 | 1200463 | B | 420356 | 1200137 | ១ | ត្រពាំងភ្លាំង | ឈូក | ឈូក |
| | | | ត្បូង | B | 420356 | 1200137 | C | 419876 | 1200035 | | | | |
| | | | | C | 419876 | 1200035 | D | 419704 | 1200133 | | | | |
| | | | លិច | D | 419704 | 1200133 | E | 419682 | 1200505 | | | | |
| | | | ជើង | E | 419682 | 1200505 | A | 420269 | 1200463 | | | | |
| ៣ | ព្រៃខ្មៅ | ១៩៧ | កើត | A | 445107 | 1211881 | B | 445679 | 1211456 | ១ | ស្រែក្នុង | ជុំគិរី | |
| | | | | B | 445679 | 1211456 | C | 446335 | 1210430 | | | | |
| | | | ត្បូង | C | 446335 | 1210430 | D | 444174 | 1210468 | | | | |
| | | | លិច | D | 444174 | 1210468 | E | 444 773 | 1211642 | | | | |
| | | | ជើង | E | 444 773 | 1211642 | A | 445107 | 1211881 | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៤ | ត្រពាំងស្ពៅ ផ្ទៃដី៣៤១ | ២៥៣ | កើត | A | 420057 | 1199876 | B | 422150 | 1198327 | ១ | ត្រពាំងក្រាំង | ឈូក | ឈូក |
| | | | ត្បូង | B | 422150 | 1198327 | C | 421914 | 1198051 | | | | |
| | | | លិច | C | 421914 | 1198051 | D | 418925 | 1198901 | | | | |
| | | | ជើង | D | 418925 | 1198901 | E | 418695 | 1199814 | | | | |
| | | | | E | 418695 | 1199814 | A | 420057 | 1199876 | | | | |
| | | ៨៨ | កើត | A1 | 417628 | 1199363 | B1 | 417219 | 1198624 | | | | |
| | | | ត្បូង | B1 | 417219 | 1198624 | C1 | 416561 | 1199062 | | | | |
| | | | លិច | C1 | 416561 | 1199062 | D1 | 417006 | 1199864 | | | | |
| | | | ជើង | D1 | 417006 | 1199864 | A1 | 417628 | 1199363 | | | | |
| ៥ | ថ្មសររូងខ្លា | ៩៩០ | កើត | A | 446657 | 1220241 | B | 446658 | 1217498 | ៣ | ស្រែចែង | ជុំគិរី | ឈូក |
| | | | ត្បូង | B | 446658 | 1217498 | C | 444484 | 1218143 | | | | |
| | | | លិច | C | 444484 | 1218143 | D | 444170 | 1218592 | | | | |
| | | | ជើង | D | 444170 | 1218592 | E | 444935 | 1220583 | | | | |
| | | | | E | 444935 | 1220583 | A | 446657 | 1220241 | | | | |
| ៦ | ជំលាក់អ្នកតាថ្មពូន ផ្ទៃដី៩៨៥ | ៨១៨ | កើត | A | 445882 | 1218146 | B | 446451 | 1217277 | ៣ | ស្រែក្នុង | ជុំគិរី | ឈូក |
| | | | | B | 446451 | 1217277 | C | 445590 | 1214204 | | | | |
| | | | ត្បូង | C | 445590 | 1214204 | D | 444679 | 1212672 | | | | |
| | | | | D | 444679 | 1212672 | E | 444493 | 1212693 | | | | |
| | | | លិច | E | 444493 | 1212693 | F | 444248 | 1218142 | | | | |
| | | | ជើង | F | 444248 | 1218142 | A | 445882 | 1218146 | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១៦៧ | កើត | A1 | 446389 | 1214929 | B1 | 446423 | 1212824 | | | | |
| | | | ត្បូង | B1 | 446423 | 1212824 | C1 | 445153 | 1213029 | | | | |
| | | | លិច | C1 | 445153 | 1213029 | D1 | 446012 | 1214653 | | | | |
| | | | ជើង | D1 | 446012 | 1214653 | A1 | 446389 | 1214929 | | | | |
| ៧ | ដំណាក់រលោះ បវរថ្មធំ | ៥៨៧ | កើត | A | 446335 | 1210430 | B | 445827 | 1208501 | ៥ | ស្រែសំរោង | ជុំគិរី | ឈូក |
| | | | | B | 445827 | 1208501 | C | 445610 | 1207170 | | | | |
| | | | ត្បូង | C | 445610 | 1207170 | D | 445229 | 1206765 | | | | |
| | | | លិច | D | 445229 | 1206765 | E | 444756 | 1206815 | | | | |
| | | | | E | 444756 | 1206815 | F | 443893 | 1208833 | | | | |
| | | | ជើង | F | 443893 | 1208833 | G | 444174 | 1210469 | | | | |
| | | | | G | 444174 | 1210469 | A | 446335 | 1210430 | | | | |
| ៨ | ភ្នំធំចំណេងសាមគ្គី | ១០១៥ | កើត | A | 429577 | 1208547 | B | 429448 | 1206519 | ១ | តាកែន | ឈូក | ឈូក |
| | | | ត្បូង | B | 429448 | 1206519 | C | 427898 | 1206904 | | | | |
| | | | លិច | C | 427898 | 1206904 | D | 424934 | 1209866 | | | | |
| | | | ជើង | D | 424934 | 1209866 | E | 424876 | 1210385 | | | | |
| | | | | E | 424876 | 1210385 | F | 426592 | 1210826 | | | | |
| | | | | F | 426592 | 1210826 | G | 427727 | 1210408 | | | | |
| | | | | G | 427727 | 1210408 | A | 429577 | 1208547 | | | | |
| | សរុប | ៣៨១៥ | | | | | | | | ១៦ | ៥ | ២ | ១ |